ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ

លេខ : ៥៦៩៧/២៣ មស.សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការតែងតាំងសមាសភាពអនុគណៈកម្មាធិការប្រតិបត្តិនៃគណៈកម្មាធិការជាតិ ជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ របស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា

## រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៣/២១៤៣ ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា
- បានឃើញអនុក្រឹត្យលេខ ៣០៩ អនក្រ.បក ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៣ ស្តីពីតួនាទីនិងភារកិច្ចរបស់ក្រសួងមុខងារសាធារណៈក្នុងក្របខណ្ឌជាលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា
- បានឃើញសេចក្តីសម្រេចលេខ ១២៥ សសរ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៣ ស្តីពីការបង្កើតអនុគណៈ-កម្មាធិការប្រតិបត្តិ និងក្រុមការងារបច្ចេកទេសនៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា
- យោងតាមការចាំបាច់

## សម្រេច

**ប្រការ១ .-**

តែងតាំងសមាសភាពអនុគណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា ដូចមានរាយនាមខាងក្រោម៖

| | | | | |
|---|---|---|---|---|
| ១. | ឯកឧត្តម | **យក់ ប៊ុនណា** | រដ្ឋលេខាធិការប្រចាំការ នៃក្រសួងមុខងារសាធារណៈ | ប្រធាន |
| ២. | លោកជំទាវ | **ឈី ទិដ្ឋារ៉ា** | រដ្ឋលេខាធិការ នៃក្រសួងមុខងារសាធារណៈ | អនុប្រធាន |
| ៣. | ឯកឧត្តម | **ម៉ុក ច័ន្ទសុធា** | រដ្ឋលេខាធិការ នៃទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៤. | ឯកឧត្តម | **ប្រាក់ សំអឿន** | រដ្ឋលេខាធិការ នៃក្រសួងមហាផ្ទៃ | សមាជិក |
| ៥. | លោកជំទាវ | **គឹម សេដ្ឋានី** | រដ្ឋលេខាធិការប្រចាំការ នៃក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៦. | ឯកឧត្តម | **រស់ សុផាន់** | រដ្ឋលេខាធិការ នៃក្រសួងមុខងារសាធារណៈ | សមាជិក |
| ៧. | ឯកឧត្តម | **ប៉ុល ពីឌូ** | រដ្ឋលេខាធិការ នៃក្រសួងមុខងារសាធារណៈ | សមាជិក |
| ៨. | ឯកឧត្តម | **ថោ សេដ្ឋាណា** | រដ្ឋលេខាធិការ នៃក្រសួងមុខងារសាធារណៈ | សមាជិក |
| ៩. | ឯកឧត្តម | **គង់ សុភី** | រដ្ឋលេខាធិការ នៃក្រសួងមុខងារសាធារណៈ | សមាជិក |
| ១០. | ឯកឧត្តម | **រោង ឈុង** | រដ្ឋលេខាធិការ នៃក្រសួងមុខងារសាធារណៈ | សមាជិក |
| ១១. | ឯកឧត្តម | **ស សារ៉ាមីឌី** | រដ្ឋលេខាធិការ នៃក្រសួងមុខងារសាធារណៈ | សមាជិក |
| ១២. | ឯកឧត្តម | **ឆាយ ឆត្រាឧត្តម** | រដ្ឋលេខាធិការ នៃក្រសួងមុខងារសាធារណៈ | សមាជិក |
| ១៣. | ឯកឧត្តម | **សំ រិទ្ធី** | រដ្ឋលេខាធិការ នៃក្រសួងមុខងារសាធារណៈ | សមាជិក |
| ១៤. | ឯកឧត្តម | **សុខ សប្បាយណា** | រដ្ឋលេខាធិការ នៃក្រសួងមុខងារសាធារណៈ | សមាជិក |
| ១៥. | ឯកឧត្តម | **សុខ សទ្ធារ** | រដ្ឋលេខាធិការ នៃក្រសួងមុខងារសាធារណៈ | សមាជិក |
| ១៦. | ឯកឧត្តម | **ឈួរ សុបញ្ញា** | រដ្ឋលេខាធិការ នៃក្រសួងមុខងារសាធារណៈ | សមាជិក |
| ១៧. | ឯកឧត្តម | **នួច សុខសម្បត្តិ** | អនុរដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១៨. | ឯកឧត្តម | **ស៊ឹម ស៊ីយ៉េង** | អនុរដ្ឋលេខាធិការ នៃក្រសួងសុខាភិបាល | សមាជិក |
| ១៩. | ឯកឧត្តម | **អិន អេម** | សមាជិក នៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ | សមាជិក |
| ២០. | ឯកឧត្តម | **ទី ហ្សានិត** | អនុរដ្ឋលេខាធិការ និងជានាយកខុទ្ទកាល័យ នៃក្រសួងមុខងារសាធារណៈ | សមាជិក |
| ២១. | ឯកឧត្តម | **ឈុន សុជាតិ** | អគ្គនាយក នៃក្រសួងមុខងារសាធារណៈ | សមាជិកអចិន្ត្រៃយ៍។ |

**ប្រការ២ .-**

ប្រធាន អនុប្រធាន សមាជិក និងសមាជិកអចិន្ត្រៃយ៍ ដូចមានចែងក្នុងប្រការ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៥ រោច ខែ កត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣ ខែ វិច្ឆិកា ឆ្នាំ២០២៣

**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**

**និងជាអនុប្រធានប្រចាំការ គ.ខ.រ.**

**ហ៊ុន_ម៉ានី**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី

  **"ដើម្បីជូនជ្រាប"**
- ដូចប្រការ២ **"ដើម្បីអនុវត្ត"**
- ឯកសារ កាលប្បវត្តិ